ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

## សេចក្ដីជូនព័ត៌មាន

## ស្ដីពីលទ្ធផលនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី៣

## (ទីក្រុងតាលី ថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៧)

*****

តាមការអញ្ជើញរបស់ ឯកឧត្តម វ៉ាង យី រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋប្រជាមានិតចិន ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះជាណាចក្រកម្ពុជា បានដឹកនាំគណៈប្រតិភូទៅចូលរួម និងធ្វើជាសហប្រធាននៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី៣ ដែលបានប្រព្រឹត្តពីថ្ងៃទី១៤ ដល់ ១៦ ខែធ្នូ ឆ្នាំ២០១៧ នៅទីក្រុងតាលី ខេត្តយូណាន សាធារណរដ្ឋប្រជាមានិតចិន។

នៅក្នុងកិច្ចប្រជុំនេះ រដ្ឋមន្ត្រីបានផ្លាស់ប្ដូរយោបល់គ្នាយ៉ាងស៊ីជម្រៅ និងបានឯកភាពជាឯកច្ឆន្ទលើការអនុវត្តលទ្ធផលនៃកិច្ចប្រជុំកំពូលកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី១ និងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី២ ទិសដៅអនាគតនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង និងការរៀបចំកិច្ចប្រជុំកំពូលកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី២។

រដ្ឋមន្ត្រីបានអបអរសាទរចំពោះការបង្កើតលេខាធិការដ្ឋានជាតិ/អង្គភាពសម្របសម្រួលកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងនៅក្នុងប្រទេសទាំងប្រាំមួយមុនកាលបរិច្ឆេទដែលបានកំណត់ ការទទួល និងការអនុម័តលើគម្រោងដំណាក់កាលទី១ដែលគាំទ្រដោយមូលនិធិពិសេស នៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង ការបង្កើតនិងដំណើរការនៃក្រុមការងាររួមលើវិស័យអាទិភាពគន្លឹះទាំងប្រាំមួយ ការបង្កើតមជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការធនធានទឹក មជ្ឈមណ្ឌលកិច្ចសហប្រតិបត្តិការបរិស្ថានមេគង្គ-ឡានឆាង និងមជ្ឈមណ្ឌលសកលសម្រាប់ការសិក្សាទន្លេមេគង្គ។ រដ្ឋមន្ត្រីបានកត់សម្គាល់ដោយសេចក្ដីសោមនស្សដែលគម្រោងឆាប់ទទួលបានផលភ្លាមៗទាំង៤៥ និងគំនិតផ្ដួចផ្ដើមទាំង១៣ ដែលបានដាក់ចេញដោយប្រទេសចិននៅក្នុងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃកិច្ចប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី២ ត្រូវបានបញ្ចប់ការអនុវត្ត ឬសម្រេចបានវឌ្ឍនភាពគួរឲ្យកត់សម្គាល់។ កិច្ចប្រជុំបានអនុម័តលើឯកសារដូចខាងក្រោម៖

១-សេចក្ដីប្រកាសរួមនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង លើកទី៣

២-បញ្ជីគម្រោងដំណាក់កាលទី១ដែលឧបត្ថម្ភដោយមូលនិធិពិសេសនៃកិច្ចសហប្រតិបត្តិការ

អាសយដ្ឋានៈ លេខ ៣ វិថី សម្ដេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

មេគង្គ-ឡានឆាង នៅឆ្នាំ២០១៧ និង

៣-ព័ត៌មានទំនាក់ទំនងទាន់ហេតុការណ៍របស់លេខាធិការដ្ឋានជាតិ/អង្គភាពសម្របសម្រួលនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាង។

គួរកត់សម្គាល់ផងដែរថា នៅក្នុងបញ្ជីគម្រោងដំណាក់កាលទី១ខាងលើ កម្ពុជាមានគម្រោងចំនួន ១៦ ដែលត្រូវបានឯកភាពសម្រាប់យកទៅអនុវត្ត និងមានទឹកប្រាក់សរុប ៧.៣១៥.៩០៨ ដុល្លារអាមេរិក។

**ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន** បានសម្តែងនូវការពេញចិត្តចំពោះប្រទេសសមាជិកមេគង្គ-ឡានឆាងទាំងអស់ដែលបានផ្តល់ការសហការយ៉ាងជិតស្និទ្ធ និងគាំទ្រខ្លាំងក្លា ឆ្ពោះទៅរកភាពជោគជ័យ និងលទ្ធផលជាវិជ្ជមាននៃកិច្ចប្រជុំកំពូលនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី២ ដែលកម្ពុជានឹងធ្វើជាសហប្រធាន និងជាម្ចាស់ផ្ទះនៃកិច្ចប្រជុំនេះ នៅថ្ងៃទី១០ ខែមករា ឆ្នាំ២០១៨ នៅរាជធានីភ្នំពេញ ក្រោមមូលបទ «ទន្លេរបស់យើងដើម្បីសន្តិភាព និងការអភិវឌ្ឍប្រកបដោយចីរភាព»។

ទន្ទឹមនឹងការអញ្ជើញចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសនៃកិច្ចសហប្រតិបត្តិការមេគង្គ-ឡានឆាងលើកទី៣ **ឯកឧត្តមទេសរដ្ឋមន្ត្រី ប្រាក់ សុខុន** បានជួបប្រជុំទ្វេភាគីជាមួយ **ឯកឧត្តម វ៉ាង យី**។ រដ្ឋមន្ត្រីទាំងពីរ បានផ្លាស់ប្តូរយោបល់ស្តីពីវិធីសាស្ត្រនានាដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី នៅមុនការប្រារព្ធខួបទី៦០នៃការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ នៅឆ្នាំក្រោយ។៚

ភ្នំពេញ ថ្ងៃទី ១៧ ខែធ្នូ ឆ្នាំ២០១៧